## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ
# រយៈពេល ៣ ឆ្នាំ
# (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : អំពិលទឹក

ភូមិ : អំពិលទឹក

ឃុំ : អំពិលទឹក

ស្រុក : កំពង់ត្រឡាច

ខេត្ត : កំពង់ឆ្នាំង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

## រយៈពេល ៣ ឆ្នាំ

## (២០០៨-២០១០)

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | : | អំពិលទឹក |
| ភូមិ | : | អំពិលទឹក |
| ឃុំ | : | អំពិលទឹក |
| ស្រុក | : | កំពង់ត្រឡាច |
| ខេត្ត | : | កំពង់ឆ្នាំង |

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ **អំពិលទឹក** ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី **១០** ខែ **កក្កដា** ឆ្នាំ **២០០៧** និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃ **១១** ខែ **មករា** ឆ្នាំ **២០០៨**។

សហគមន៍នេសាទ **អំពិលទឹក** មានទីតាំងស្ថិតនៅក្នុងភូមិ **អំពិលទឹក** ឃុំ **អំពិលទឹក** ស្រុក **កំពង់ត្រឡាច** ខេត្ត **កំពង់ឆ្នាំង** ដែលមានសមាជិកសរុបចំនួន **២៤៣** នាក់ ស្រីចំនួន **១២៩** នាក់ និងមានគណៈកម្មការចំនួន **៩** នាក់ ស្រីចំនួន **៣** នាក់។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន **៧៨** គ្រួសារ ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមាន ៖

- លក្ខន្តិកៈសហគមន៍នេសាទ និងបទបញ្ជាផ្ទៃក្នុង
- ផែនទីសហគមន៍
- កិច្ចប្រមព្រៀង
- កន្លែងអភិរក្ស
- បណ្ដុះកូនឈើប្រភេទព្រៃលិចទឹក
- សាងសង់ស្នាក់ការសហគមន៍
- សហការជាមួយមេភូមិ និងក្រុមប្រឹក្សាឃុំ
- សហការជាមួយជំនាញជលផល

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាជនរស់នៅ:

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន **៦៤៣** នាក់ **១២២** គ្រួសារ បុរស **២៨៦ នាក់** ស្រី **៣៥៧** នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន **៦៤៣** នាក់ ខ្មែរឥស្លាមចំនួន **គ្មាន** អាណិកជនវៀតណាម **គ្មាន**។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ១១ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ៣ នាក់ ស្រី គ្មាន
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៨ នាក់ ស្រី ៦ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន គ្មាន ស្រី គ្មាន
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន ៣ នាក់ ស្រី ៣ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ **១០០%**។ ក្រៅពីនេះមានអ្នកកាន់សាសនា អ៊ិស្លាម ប្រមាណ **គ្មាន** សាសនាកាតូលិក **គ្មាន**

- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន **១២** នាក់ ស្រី **៦** នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន **២២៧** នាក់ ស្រី **១២២** នាក់ កំរិតមធ្យមសិក្សាចំនួន **១៦** នាក់ ស្រី **៧** នាក់ និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន **គ្មាន** ។

**ខ-មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមានៈ

- ធ្វើនេសាទចំនួន ១២៣ គ្រួសារ
- ធ្វើស្រែប្រាំងចំនួន ១២៣ គ្រួសារ ទំហំ ១៣០ហិកតា
- ធ្វើវារីវប្បកម្មចំនួន ៨ គ្រួសារ ទំហំ ០,០៩ហិកតា តាមស្រះចិញ្ចឹមត្រីអណ្តែង និងប្រា (១០ម x ១៥ម)
- ដាំបន្លែចំនួន ៨០ គ្រួសារ ទំហំ ០,៥ ហិកតា
- ជាងផ្ទះចំនួន ៥ គ្រួសារ
- ធ្វើសិប្បកម្មចំនួន ១៥ គ្រួសារ (ត្បាញកន្ទេល)
- ចិញ្ចឹមសត្វ ១២៣គ្រួសារ
- លក់ដូរ ចំនួន ៦ គ្រួសារ (លក់ចាប់ហួយ)
- កែច្នៃផលនេសាទ ៥០ គ្រួសារ ធ្វើត្រីឆ្អើ និង ប្រហុក
- ជាងកាត់សក់ ២ គ្រួសារ
- ឡក់កំលាំងពលកម្ម ៣០ គ្រួសារ

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍ **អំពិលទឹក** ជាកន្លែងដែលត្រូវបានកាត់ចេញពីឡូត៍នេសាទ លេខ **២០** និងជាដែននេសាទទឹកសាប ។

កន្លែងនេសាទសហគមន៍ **អំពិលទឹក** មានទំហំ **២៣៨៤** ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ :

- ខាងជើងទល់នឹង **ដើមតាសេកនៃភូមិស្តីបន្ទិច**
- ខាងត្បូងទល់នឹង **ភូមិស្ទឹងស្ងួត (ជីទូប៉េង)**
- ខាងកើតទល់នឹង **ចុងបឹង ព្រំប្រទល់ខេត្តកំពង់ចាម**
- ខាងលិចទល់នឹង **ទន្លេកប៉ាល់**

### ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ **អំពិលទឹក** មានបឹងចំនួន **៩** ព្រែកចំនួន **គ្មាន** ប្រឡាយចំនួន **គាន** ត្រពាំងចំនួន **៣** បឹងចំនួន **គ្មាន** និង មេទឹក **១២** ។

- បឹងឈ្មោះ **កន្លែងមូល** ទំហំ ៥០ម x ៥០ x ១ នេសាទពីខែ កុម្ភៈ ដល់ខែ មេសា
- បឹងឈ្មោះ **ក្បាលក្រពើ** ទំហំ ១៥០ x ២០ x ២ នេសាទពីខែ កុម្ភៈ ដល់ខែ មេសា
- បឹងឈ្មោះ **ទូលចា** ប្រវែង ១០០ x ១០០ x ២ នេសាទពីខែ កុម្ភៈ ដល់ខែ មេសា
- បឹងឈ្មោះ **បត់ចញ្ចៀន** ប្រវែង ៥០ x ៥០ x ១ នេសាទពីខែ កុម្ភៈ ដល់ខែ មេសា
- បឹងឈ្មោះ **តាព្រីង** ប្រវែង ៦០ x ៧០ x ១ នេសាទពីខែ កុម្ភៈ ដល់ខែ មេសា
- ត្រពាំងឈ្មោះ **កន្លែងលាវកូនថ្ងោល** ទំហំ ៥០ x ៥០ x ១.៥ នេសាទពីខែ មករា ដល់ខែ កុម្ភៈ
- ត្រពាំងឈ្មោះ **កន្លែងវែង** ទំហំ ៣០ x ៣០ x ១ នេសាទពីខែ មករា ដល់ខែ កុម្ភៈ
- ត្រពាំងឈ្មោះ **កន្លែងតាអូរ** ទំហំ ៤០ x ៤០ x ១ នេសាទពីខែ មករា ដល់ខែ កុម្ភៈ
- អាងទឹកឈ្មោះ **ស្វាខម** ទំហំ ១៥០០ x ២០០ x ២ នេសាទពីខែ កក្កដា ដល់ខែ ឧសភា
- អាងទឹកឈ្មោះ **ទំនប់ថ្មី** ទំហំ ១៣០០ x ១៥០ x ២,៥ នេសាទពីខែ កក្កដា ដល់ខែ ឧសភា
- អាងទឹកឈ្មោះ **ព្រៃអំបែង** ទំហំ ២៣០០ x ៥០០ x ១,៥ នេសាទពីខែ កក្កដា ដល់ខែ ឧសភា
- អាងទឹកឈ្មោះ **ក្រឡាប់** ទំហំ ១៥០០ x ៥០០ x ១ នេសាទពីខែ កក្កដា ដល់ខែ ឧសភា
- អាងទឹកឈ្មោះ **ប្រាំងថ្មី** ទំហំ ៥០០ x ៩០០ x ១,៥ នេសាទពីខែ កក្កដា ដល់ខែ ឧសភា
- អាងទឹកឈ្មោះ **ចំការឈូក** ទំហំ ៥០០ x ៥០០ x ១ នេសាទពីខែ កក្កដា ដល់ខែ ឧសភា
- អាងទឹកឈ្មោះ **បាត់មូល** ទំហំ ៥០០ x ៦០០ x ១ នេសាទពីខែ កក្កដា ដល់ខែ ឧសភា
- អាងទឹកឈ្មោះ **ក្បាលដំរី** ទំហំ ១៥០០ x ៨០០ x ១,៥ នេសាទពីខែ កក្កដា ដល់ខែ ឧសភា
- អាងទឹកឈ្មោះ **ផ្ដៅ** ទំហំ ៧០០ x ៥០០ x ១,៥ នេសាទពីខែ កក្កដា ដល់ខែ ឧសភា
- អាងទឹកឈ្មោះ **កន្លែងស្មោរ** ទំហំ ១៥០០ x ៤០០ x ១ នេសាទពីខែ កក្កដា ដល់ខែ ឧសភា
- អាងទឹកឈ្មោះ **ពន្លាយ** ទំហំ ៥០០ x ៣០០ x ១ នេសាទពីខែ កក្កដា ដល់ខែ ឧសភា
- អាងទឹកឈ្មោះ **ព្រៃកសសៃ** ទំហំ ១៧៥០០ x ៣៥០ x ២ នេសាទពីខែ កក្កដា ដល់ខែ ឧសភា
- ស្រះមាន ៩គ្រួសារ
- ព្រៃលិចទឹកទំហំសរុប ២២ ហិកតា
- ព្រៃឈ្មោះ **ទំនប់ព្រៃកសសៃ** ទំហំ ៦ ហិកតា
- ព្រៃឈ្មោះ **ស្វាខម** ទំហំ ២ ហិកតា
- ព្រៃឈ្មោះ **ព្រៃអំបែង** ទំហំ ១០ ហិកតា
- ព្រៃឈ្មោះ **ក្រឡាប់** ទំហំ ៣ ហិកតា
- ដីទំនាបលិចទឹកមានទំហំ **២៣៨៤** ហិកតា ទំនប់ប្រាំងថ្មី ១ ហិកតា

**ឥ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

- បឹងឈ្មោះ **ទូលចារ** ទំហំ ២ ហិកតា ( បណ្ដោយ ១០០ម ទទឹង ១០០ម x ១ម)

- ព្រៃឈ្មោះ **ព្រៃកសសៃ** ទំហំ ១០ ហិកតា

## ឃ. ធនធានផលផល

**ប្រភេទត្រី :**

- ប្រភេទត្រីដែលមានការថយចុះ: គ្រំ, កំពូលបាយ, កញ្ជន, គន្ធ, ឆ្តោរ, ព្រួល, ខ្វាន់, លិញ, ក្រឡុងកាហោរ, ព្រលូង, ឆ្កោក, ខ្យា, សណ្តាយ, ក្រពាត់, ប្រម៉ា, ព្រាម, បណ្តូលអំពៅ ។
- ប្រភេទត្រីដែលមិនថយ និងមិនកើនឡើង : ក្រុស, រ៉ស់, អណ្តែង, ច្រកែង,ឆ្តាំង, ក្រាញ់, រៀល, កំភ្លាញ, កញ្ចុះ, កន្ត្រប់, ជន្ទាស់ភ្លុក, ចង្វា, កន្ទ្រងប្រេង, ឆ្ពិន, ប្រា, ច្រឡឹង, ស្រកាវក្តាម, កំបុតច្រមុះ, កញ្ជ្រូក, កញ្ជាស់ ។
- **ប្រភេទវារីសត្វ :** អណ្តើក កន្ធាយ ពស់ ស្វា អន្សង និងភេ គីង្គក់ ក្រពើ (ថយចុះ) ក្តាម ខ្យង ខ្ចៅ កំពិស កង្កែប (នៅដដែល) ។

**ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ** : បបុស, ត្រសេក, ចា ខ្ទុំ ច្រកែង ថ្មើមអណ្តើក ចំបលង អណ្តូងព្រះ ស្លាបគុប ឃ្លេ ល្បៀង (ថយចុះ) រាំង ត្រស់ ព្រលិត ត្រកួន់ អញ្ចាញ បបួយ ក្អែក វល្លិផុយ ញ កន្ទ្រាងហៃ វល្លិប្រេង បន្លាស្អិត ត្រដិត ដើមធ្មេញកញ្ចុះ ឃ្លេ ល្បៀង ។

## ៤. ការធ្វើនេសាទ

## ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន **២៤៣** នាក់ ស្រី **១២៩** នាក់ **៧៨** គ្រួសារ
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន **១១៥** នាក់ ស្រី **៦៤** នាក់**៤៤** គ្រួសារ ។
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន **១០០** នាក់ ស្រី **៥០** នាក់

## ៥. ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ:

| **ប្រភេទឧបករណ៍** | **ឯកតា** | **ចំនួន** | **ទំហំ/ប្រវែង** | រដូវប្រើប្រាស់ឧបករណ៍ (ខែ.......ដល់ ខែ........) |
|---|---|---|---|---|
| មងពាក់ | ម៉ែត្រ | ៣៦៩០០ម | ៣៦៩០០ម | ពេញ ១ ឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៥០០ផ្លែ x ៣០ នាក់ = ១៥០០០ ផ្លែ | ១៥០០០ ផ្លែ | មិថុនា |
| លបត្រីរស់ | គ្រឿង | ២០ គ្រឿង | ២០គ្រឿង | តុលា-ធ្នូ |
| អួន | វង់ | ៤ វង់ | ៤ វង់ | កុម្ភៈ-មិនា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ |
|---|---|---|
| ទូកគ្មានម៉ាស៊ីន | ៥០គ្រឿង | ៥០០ គក្រ |
| ទូកម៉ាស៊ីន | ១០០គ្រឿង | ៥០០-១០០០គក្រ |

- ឧបករណ៏នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៏នេសាទ:

**ចូលទាំងអស់គ្នាជាសមាជិកសហគមន៍នេសាទ**

| ប្រភេទឧបករណ៏ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មង | ម៉ែត្រ | ៩០០០០ម | ៩០០០០ម |
| សន្ទូចរនង | ផ្លែ | ៥០០ផ្លែ x ៣០ នាក | ១៥០០០ ផ្លែ |
| អួន | វង់ | ៣០នាក់ x ៣វង់ | ៩០ វង់ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកឈើ | ៤៤ គ្រឿង | ៣០០-៥០០ គក្រ | ៣-៧សេះ |
| ទូកត្នោត | ៤ គ្រឿង | ផ្ទុកម្នាក់ឯង | គ្មានម៉ាស៊ីន |

- ឧបករណ៏នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៏នេសាទ:

| ប្រភេទឧបករណ៏ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មង | ម៉ែត្រ | ៩០នាក់ x ៥០០ម | ៤៥០០០ ម |
| អួនអូសដៃ | វង់ | ១ វង់ x ១០នាក់ | ១០ វង់ |
| សន្ទូចរប៉ង្កៃ | ផ្លែ | ២០នាក់ x ១០០ផ្លែ | ២០០០ ផ្លែ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីន | ១០០ គ្រឿង | ១០០០ គក្រ | ៥-៧សេះ |
| ទូកត្នោត | ១០ គ្រឿង | ជិះម្នាក់ឯង | គ្មានម៉ាស៊ីន |

## គ. ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (*គិតជា គក*) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី គ្រប់ប្រភេទ | ២៧៦០០ គក្រ | ២៩៥០០ គក្រ | ៥៧១០០ គក្រ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទ **អំពិលទឹក** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹកក្នុងរដូវជំឡើងនាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការ ចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| បឹងកន្លែងមូល | កម្ភៈ-មេសា | មងរាយ.សន្ទូច | ២៤០០ម | ៣០គ្រួសារ | ២៥០០ផ្លែ |
| ក្បាលក្រពើ | កម្ភៈ-មេសា | មងរាយ.សន្ទូច | ១៦០០ម | ២០គ្រួសារ | ១៥០០ផ្លែ |

### គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ទំនប់ព្រៃកសសៃ | ១០ ហត | ១០០មx១០០x៣ | ជីកអោយជ្រៅ | មេសា ២០០៨ | ឧសភា ២០០៩ | |

### គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ព្រៃកសសៃ | ១០០មx១០០ | អភិរក្សត្រីមេពូជ | ជីក | មេសា ២០០៨ | ឧសភា ២០០៩ | |

### គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំនិងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១-ដាំព្រៃលិចទឹកព្រៃកសសៃ | ១០០មx១០០ម | រាំង ច្រកែង គ្រោះ ទន្លា | ដាំឡើងវិញ | កក្កដា ២០០៨ | កក្កដា ២០០៩ | |
| ២-ថែរក្សា និងរំលោះព្រៃលិចទឹក | ថែរក្សា | ថែរក្សា | ថែរក្សា | ២០០៨ | ២០១៣ | |

### គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្មឈ

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ស្រះ | ៨ | ឆ្ពិន.អណ្តែង | ១៦០០០កូន | ២០០៩ | ២០១១ |

## គ-៦ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | | | | | |
| ភាគទានប្រចាំឆ្នាំ | | ពុំទាន់ចាប់ផ្ដើម | | | |
| ជំនួយសប្បុរសជន និងអង្គការនានា | គ្មាន | គ្មាន | គ្មាន | គ្មាន | |

## គ-៧ ផែនការចិញ្ចឹមសត្វ

ដោយយោងលើសហគមន៍នេសាទត្រូវការចាំបាច់ផងដែរនូវផលិតផលដែលបានមកពីការចិញ្ចឹមសត្វព្រោះសត្វទាំងនេះអាចផ្ដល់នូវប្រាក់បន្ថែម និងជាអាហារផ្ដល់ប្រូតេអ៊ីនដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ ជួយកាត់បន្ថយភាពក្រីក្រ ។ ការចិញ្ចឹមសត្វនេះគណៈកម្មការសហគមន៍នេសាទមានផែនការសរសេរគម្រោងស្នើសុំទៅដល់ម្ចាស់ជំនួយផ្សេងៗដូចជាអង្គការ ហ្វារ គំរោងទន្លេសាប រឺគម្រោងរដ្ឋាភិបាលជាដើម ។

***តារាងផែនការចិញ្ចឹមសត្វ***

| ប្រភេទសត្វចិញ្ចឹម | សកម្មភាព | គ្រួសារ | បិមាណសត្វក្នុង១គ្រួសារ | បរិមាណសត្វសរុប | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| មាន់ | - បង្រៀនដល់សមាជិកពីការចិញ្ចឹម<br>-ផ្ដល់ពូជញី ចំនួន៣ និងឈ្មោល១ក្បាលក្នុង១គ្រួសារ<br>-សមាជិកថែរក្សា និងផ្ដល់ចំណី<br>- តាមដានជំងឺសត្វ និងកត់ត្រា<br>-ពេលមានសត្វមានកូនត្រូវផ្ដល់កូនញី៣ ឈ្មោល១ក្បាលដល់គ្រួសារផ្សេងទៀតដែលមិនទាន់បានចិញ្ចឹម<br>- សរសេរបាយការណ៍រៀងរាល់ខែ<br>- ទំនាក់ទំនងល្អជាមួយមន្ត្រីជំនាញ | ៨០ | ៤ ក្បាល | ៣២០ក្ប | ខែ១២/០៨ | ខែ០៦/០៩ |
| ទាកាឡាបា | សកម្មភាពដូចមាន់ដែរ | ៥០ | ៣ ក្បាល | ១៥០ក្ប | ខែ១២/០៧ | ខែ៦/០៨ |
| គោ | - បង្រៀនដល់សមាជិកសហគមន៍នេសាទពីការចិញ្ចឹមគោដូចជាការផ្ដល់ចំណី រោគសញ្ញានៃ ជម្ងឺ របៀបព្យាបាលដែលអាចធ្វើបានការថែទាំ និងការឱ្យលំចំណីជាដើម ។<br>-ផ្ដល់ពូជញី ចំនួន៧ និងឈ្មោល១ ( បា)<br>-សមាជិកថែរក្សា និងផ្ដល់ចំណី | ៨ | ១ ក្បាល | ៨ | ខែ៣/០៨ | ខែ៣/១១ |

| | | | | | | |
|---|---|---|---|---|---|---|
| | - តាមដានជំងឺសត្វ<br>- សរសេរបាយការណ៍រៀងរាល់ខែ<br>- ទំនាក់ទំនងល្អជាមួយមន្ត្រីជំនាញ<br>-ពេលបានកូនគោធំអាចបង្វិលទៅសមាជិក ផ្សេងទៀត។ | | | | | |
| ជ្រូក | - បង្រៀនដល់សមាជិកសហគមន៍នៃសាទ ពីការចិញ្ចឹមគោដូចជាការផ្តល់ចំណី រោគ សញ្ញានៃជម្ងឺ ការថែទាំ និងការឱ្យល់ចំណី ជាដើម។<br>-ផ្តល់កូនជ្រូកញី១ក្បាល និងឈ្មោល១ (បា)<br>-សមាជិកថែរក្សា និងផ្តល់ចំណី<br>- តាមដានជំងឺសត្វ<br>-ពេលមានសត្វមានកូនត្រូវផ្តល់កូន២ រឺ៣ ក្បាលដល់គ្រួសារផ្សេងទៀតដែលមិនទាន់បាន<br>- សរសេរបាយការណ៍រៀងរាល់ខែ | ២៥ | ១ ក្បាល | ២៥ក្បាល | ខែ១២/០៨ | ខែ៩/០៩ |

## គ-៤ ផែនការបង្កើតក្រុមសន្សំប្រាក់

ការបង្កើតប្រាក់សន្សំនេះគណៈកម្មការនឹងផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការបង្កើតក្រុមសន្សំប្រាក់ដោយធ្វើការប្រៀបធៀប លើការខ្ចីប្រាក់ពីធនាគារឯកជនដែលគេយកការប្រាក់ខ្ពស់ ហើយបំពេញឯកសារច្រើន។ តែចំពោះក្រុមសន្សំគឺយើងត្រូវធ្វើលិខិតស្នើសុំ ទៅម្ចាស់ជំនួយដូចជាអង្គការក្រៅរដ្ឋាភិបាល គម្រោងរដ្ឋាភិបាល និងសប្បុរសជននានា ។ល។

| ប្រាក់ទុនដែលស្នើរសុំ | បដិភាគរបស់សមាជិកដែលចងក្រងជាក្រុម | ចំនួនសមាជិកក្នុងក្រុមសន្សំ | ប្រាក់សរុបក្នុង១ឆ្នាំ | សកម្មភាព | អត្រាការប្រាក់ |
|---|---|---|---|---|---|
| ៦.០០០.០០០ | ៣០.០០០/នាក់ | ១៥ គ្រួសារ | ៦០៣០០០០ | -ទុកប្រាក់ក្នុងបេឡាក្រុមសន្សំ ដើម្បីឱ្យសមាជិកក្នុងក្រុមខ្ចី<br>-ប្រធានក្រុមសន្សំត្រូវធ្វើកិច្ចសន្យាជាមួយអ្នកខ្ចីប្រាក់ | ១%ក្នុង១ខែ |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចំណេះដឹងល្អជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈ ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្ស ព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | |
| ២. ការកែលំអដែននេសាទ | -ស្តារទំនប់ព្រែកសសៃ<br>-ប្រជាពលរដ្ឋ ចូលរួមកំណត់ចំនុច<br>-ជួលគ្រឿង ចក្រមកជីក<br>-អាចម៍ដីដាក់ ផ្លូវ | -ព្រែកជ្រៅនាំឱ្យមានទឹកសំបូរ<br>-សំបូរត្រី និងវារីជាតិ<br>-ជីវភាពប្រជាពលរដ្ឋមានការកើនឡើងវិញ។ | ៣៥០០ ដុល្លា | គម្រោងរដ្ឋាភិបាល | មេសា ឆ្នាំ ២០០៨ | ឧសភា ឆ្នាំ ២០០៩ | |
| ៣. ការកំណត់ និងរៀបចំតំបន់អភិរក្ស *បឹងតាអោន* | -បោះបង្គោលឈើព្ទ័ជុំវិញ កន្លែងអភិរក្ស<br>- ដាក់ផ្លាកសញ្ញា - ប៉មយាម<br>- ទំលាក់លូសប្បនិម្មិត -ចុះល្បាតជាប្រចាំ<br>- ផ្សព្វផ្សាយទៅដល់ ប្រជាពលរដ្ឋតាមរយៈប្រជុំភូមិ និងឃុំ<br>-គណៈកម្មការនិងក្រុម ល្បាតចុះជួយធ្វើតំបន់អភិរក្ស | -សំបូរត្រី<br>-ជីវភាពកើនឡើង<br>-ប្រជាពលរដ្ឋមានការសប្បាយចិត្តដោយកំណត់កន្លែច្បាស់លាស់ | ១៩០០ ដុល្លា | គម្រោងរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល | មេសា ឆ្នាំ ២០០៨ | មេសា ឆ្នាំ ២០០៩ | |
| ៤-ផែនការគ្រប់គ្រង ព្រៃលិចទឹក | -ដាំព្រៃលិចទឹកនៅ ទំនប់ព្រែកសសៃ<br>-ប្រជាជនចូលរួមដាំកូនឈើ<br>-សហគមន៍បណ្តុះកូនឈើ<br>-សិស្សសាលាចូលរួមដាំកូនឈើ<br>-ផ្សព្វផ្សាយប្រជាពលរដ្ឋ<br>-ដាក់ផ្លាកសញ្ញា | -សំបូរព្រៃ និងត្រី<br>-សំបូរសត្វស្លាប<br>-សំបូរសត្វល្អិតចាចំណីត្រី<br>-មានលំនឹងបរិស្ថាន | ៣០០ ដុល្លា | គម្រោងរដ្ឋាភិបាល /ហ្វាវ/ អង្គការក្រៅរដ្ឋាភិបាល | កក្កដា ឆ្នាំ ២០០៨ | កក្កដា ឆ្នាំ ២០០៩ | |
| ៥-ផែនការអភិ | -សរសេរគម្រោងស្នើរសុំទៅ ម្ចាស់ជំនួយ | -បង្កើនជីវភាព | ២០០ ដុល្លា | គព្រោមាងគ្រប់គ្រង | ខែ១២ ឆ្នាំ | ខែ ៧ ឆ្នាំ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីក្នុងស្រះ | [illegible] ពីបច្ចេកទេសចិញ្ចឹមត្រី<br>-តាមដានការងារចិញ្ចឹមទាំងផ្តល់ ចំណីក៏ដូចជាថែរក្សាគុណភាពទឹក ។<br>-សរសេរបាយការ និងវាយតម្លៃ<br>-កាត់៥០%នៃកូនត្រីដែលបានផ្តលឱ្យទៅគ្រួសារដែលចង់ចិញ្ចឹមបន្តទៀត | [illegible] ប្រយោជន៏លើការចិញ្ចឹមត្រី | | | | | |
| ៦- ផែនការចិញ្ចឹមសត្វមាន់ | -បង្រៀនដល់សមាជិកដែលទទួលការចិញ្ចឹម<br>-ផ្តល់ពូជញី ចំនួន៣និងឈ្មោល១ក្បាលក្នុង១គ្រួសារ ។<br>-សមាជិកថែរក្សា និងផ្តល់ចំណី<br>-តាមដានជំងឺសត្វ<br>-ពេលមានសត្វមានកូនត្រូវផ្តល់កូនញី២ឈ្មោល១ក្បាលដល់គ្រួសារផ្សេងទៀតដែលមិនទាន់បានចិញ្ចឹម<br>-សរសេរបាយការណ៏រៀងរាល់ខែ<br>-ទំនាក់ទំនងជាមួយអ្នកបច្ចេកទេស | -ប្រជាពលរដ្ឋមានចំណេះដឹងលើការចិញ្ចឹមមាន់<br>-ប្រជាពលរដ្ឋមានជីវភាពកើនឡើង<br>-បានប្រាក់ចំណូលបន្ថែម<br>-ប្រជាជនមានសុវត្ថិភាពស្បៀង | ៨០០ ដុល្លា | គម្រោងរដ្ឋាភិបាល/ហ្វាវ/អង្គការក្រៅរដ្ឋាភិបាល.... | ខែ១២ ឆ្នាំ ២០០៨ | ខែ៦ឆ្នាំ ២០០៩ | |
| ៧- ផែនការចិញ្ចឹមសត្វទាកាឡាប៉ា | ដូចគ្នានិងមាន់ | ដូចគ្នានឹងមាន់ | ៥០០ ដុល្លា | ដូចគ្នានិងមាន់ | ខែ១២ ឆ្នាំ ២០០៨ | ខែ ៦ ឆ្នាំ ២០០៩ | |
| ៨- ផែនការចិញ្ចឹមសត្វជ្រូក | - បង្រៀនដល់សមាជិកសហគមន៏នេសាទពីការចិញ្ចឹមគោដូចជាការផ្តល់ចំណី រោគសញ្ញានៃជម្ងឺ ការថែទាំ និងការឱ្យលំចំណី ជាដើម ។<br>-ផ្តល់កូនជ្រូកញី១ក្បាល និងឈ្មោល១ (បា)<br>-សមាជិកថែរក្សា និងផ្តល់ចំណី | -ប្រជាពលរដ្ឋមានការយល់ដឹងពីការចិញ្ចឹមជ្រូក ។<br>- ប្រជាពលរដ្ឋមានជីវភាពកើនឡើង ។ | ៩៥០ ដុល្លា | គម្រោងរដ្ឋាភិបាល/ហ្វាវ/អង្គការក្រៅរដ្ឋាភិបាល.... | ខែ ១២ ឆ្នាំ ២០០៨ | ខែ ៩ ឆ្នាំ ២០០៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | -តាមដានជំងឺសត្វ<br>-ពេលមានសត្វមានកូនត្រូវផ្តល់កូន២ រឺ៣ ក្បាលដល់គ្រួសារផ្សេងទៀតដែលមិនទាន់បាន<br>- សរសេរបាយការណ៍រៀងរាល់ខែ | | | | | | |
| ៩- ផែនការចិញ្ចឹមបត្តគោ | - បង្រៀនដល់សមាជិកសហគមន៍នៃសាទពីការចិញ្ចឹមគោដូចជាការផ្តល់ចំណី រោគសញ្ញានៃ ជម្ងឺ របៀបព្យាបាលដែលអាចធ្វើបានការថែទាំ និងការឱ្យលចំណីជាដើម ។<br>-ផ្តល់ពូជញី ចំនួន១១ និងឈ្មោល១ ( បា)<br>-សមាជិកថែរក្សា និងផ្តល់ចំណី<br>- តាមដានជំងឺសត្វ<br>- សរសេរបាយការណ៍រៀងរាល់ខែ<br>- ទំនាក់ទំនងល្អជាមួយមន្ត្រីជំនាញ<br>-ពេលបានកូនគោធំអាចបង្វិលទៅសមាជិកផ្សេងទៀត ។ | -ប្រជាពលរដ្ឋមានការយល់ដឹង ពីការចិញ្ចឹមគោ ។<br>- ប្រជាពលរដ្ឋមានជីវភាពកើនឡើង ។<br>-ជាកំលាំងអូសទាញការងារកសិកម្ម<br>-បានប្រាក់ចំណូលបន្ថែម | ៣០០០ ដុល្លា | គម្រោងរដ្ឋាភិបាល/ហ្វាវ/ អង្គការក្រៅរដ្ឋាភិបាល.... | ខែ១២ ឆ្នាំ ២០០៨ | ខែ ៦ ឆ្នាំ ២០០៩ | |

| សកម្មភាព | ២០០៨ | | | | | | | | | | | | ២០០៩ | | | | | | | | | | | | ២០១០ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ |
| ១.ការប្រើប្រាស់ឧបករណ៍នេសាទ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | |
| ២. ការកែលំអដែន នេសាទ | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | |
| ៤. ផែនការគ្រប់គ្រង ព្រៃលិចទឹក | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | |
| ៥.ផែនការអភិវឌ្ឍនវារីវប្បកម្មតាមស្រះ | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | |
| ៦ ផែនការចិញ្ចឹមសត្វ | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | |
| ៧. ប្រាក់ចំណូល | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | |

សំពៅលូន ថ្ងៃទី...៩.....ខែ...៩.........ឆ្នាំ ២០០8

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

លេខ :.02.ន.ល

បានឃើញ និងបញ្ជូនមក

លោកនាយអធិការដ្ឋាន .រដ្ឋបាលជលផល

...........ថ្ងៃទី..21..ខែ.10.....ឆ្នាំ ២០០8

**នាយខណ្ឌរដ្ឋបាលជលផល**............

**បានឃើញ**

**មេឃុំ**..សំពៅលូន...

...............ថ្ងៃទី..10......ខែ.....9........ឆ្នាំ ២០០8

លេខ :..424ខឃ

បានឃើញ និងបញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ"

...........ថ្ងៃទី.....27.....ខែ......11.......ឆ្នាំ ២០០8

**នាយអធិការដ្ឋាន រដ្ឋបាលជលផល**..............

បានឃើញ និងបញ្ជូនមក

លោកនាយខណ្ឌរដ្ឋបាលជលផល

**នាយសង្កាត់រដ្ឋបាលជលផល**...........

...........ថ្ងៃទី.......10...ខែ.........9.......ឆ្នាំ ២០០8

លេខ :.................

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ  ថ្ងៃទី...........ខែ.............ឆ្នាំ ២០០

**ប្រតិភូរាជរដ្ឋាភិបាល  ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**